# សកម្មជនសិទ្ធិមនុស្សថា កម្ពុជាងាកឆ្ងាយពីប្រជាធិបតេយ្យ

ដោយ យន់ សាមៀន
2011-01-24

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅថ្ងៃអាទិត្យ ទី២៣ មករា ឆ្នាំ ២០១១ បានចេញសេចក្តីថ្លែងការណ៍មួយ ដោយបានសំដែងក្តីបារម្ភចំពោះកិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាល កម្ពុជា ដើម្បីរឹតត្បិតសិទ្ធិសេរីភាព។




*គេហទំព័ររបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា។*

មន្ត្រីសិទ្ធិមនុស្ស និងសហជីពនៅកម្ពុជា នៅថ្ងៃអាទិត្យ ទី២៣ មករា ឆ្នាំ២០១១ បានចាត់ទុកសេចក្តីព្រាងច្បាប់សហជីព និងសេចក្តីព្រាងច្បាប់សមាគមដែលបានផ្តួចផ្តើមដោយរដ្ឋាភិបាលកម្ពុជានឹងនាំកម្ពុជាងាកកាន់តែឆ្ងាយចេញពីគន្លងប្រជាធិបតេយ្យថែមទៀត។

សេចក្តីថ្លែងការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបន្តទៀតថា សេចក្តីព្រាងច្បាប់សហជីព និងសមាគមបានតម្រូវឲ្យអង្គការក្រៅរដ្ឋាភិបាល សមាគម និងសហជីពចុះបញ្ជីដ៏ស្មុគស្មាញ និងរាយការណ៍ពីហិរញ្ញវត្ថុរបស់ខ្លួន ដែលអាចបណ្តាលឲ្យសិទ្ធិសេរីភាពខាងសមាគមស្ថិតក្នុងភាពគ្រោះថ្នាក់ ដោយសារតែនីតិវិធីការិយាធិបតេយ្យនេះ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបានកត់សំគាល់ថា ចាប់តាំងពីការបោះឆ្នោតថ្នាក់ជាតិ ២០០៨ មក រដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់តុលាការកម្ពុជាជាឧបករណ៍គាបសង្កត់ និងបង្ក្រាបដល់សេរីភាពបញ្ចេញមតិ ដូចជាតំណាងរាស្ត្រគណបក្សប្រឆាំង អ្នកកាសែត មេធាវី និងសកម្មជនសិទ្ធិមនុស្សជាដើម។

ក្រសួងការបរទេសសហរដ្ឋអាមេរិក កាលពីថ្ងៃទី១២ មករា ឆ្នាំ ២០១១ ក៏បានសំដែងក្តីកង្វល់ និងសេចក្តីព្រាងច្បាប់គ្រប់គ្រងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ហើយបានសម្តែងការជំទាស់ទៅនឹងការប៉ុនប៉ងណាមួយ ពីសំណាក់រដ្ឋាភិបាលកម្ពុជាក្នុងការរឹតត្បិតសកម្មភាពស្របច្បាប់របស់អង្គការមិនមែនរដ្ឋាភិបាល។

សហរដ្ឋអាមេរិកបានស្នើឲ្យរដ្ឋាភិបាលកម្ពុជាពិភាក្សាជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា និងដៃគូរអភិវឌ្ឍរបស់កម្ពុជា ដើម្បីធ្វើការពិចារណាឡើងវិញថា តើវិធានការណ៍ទាំងឡាយចែងក្នុងសេចក្តីព្រាងច្បាប់នោះ វាមានការចាំបាច់ដែរ ឬទេ។ សហរដ្ឋអាមេរិកជឿជាក់ថា សង្គមស៊ីវិលខ្លាំងប្រកបដោយសេរីភាព គឺកម្លាំងពិសេសមួយ ដើម្បីពង្រឹងស្ថាប័នប្រជាធិបតេយ្យ និងពង្រីកកំណើនសេដ្ឋកិច្ច។

លោក រ៉ុង ឈុន ប្រធានសហភាពការងារកម្ពុជា និងសមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា នៅថ្ងៃអាទិត្យ ទី២៣ មករា មានប្រសាសន៍ប្រាប់វិទ្យុអាស៊ីឲ្យដឹងថា សហជីពនៅកម្ពុជាកំពុងមានការព្រួយបារម្ភចំពោះសេចក្តីព្រាងច្បាប់សហជីព ដែលអាចបណ្តាលឲ្យសេរីភាពសហជីពនៅកម្ពុជាធ្លាក់ចុះខ្សោយ។ លោក



Radio Free Asia
2025 M Street NW, Suite 300
Washington DC 20036, USA
202-530-4900
khmweb@rfa.org



## អត្ថបទដែលទាក់ទង

CCHR ចេញសេចក្តីថ្លែងការណ៍ចំពោះករណីសកម្មជនអាដហុក

តុលាការសម្រេចឲ្យសកម្មជនអាដហុកចាញ់ក្តីក្រុមហ៊ុន KDC

របាយការណ៍ប្រចាំឆ្នាំរបស់អង្គការ Human Rights Watch

គ្រីស្តូហ្វ ប៉េស៊ូ សង្ស័យថាតុលាការកាត់ក្តីសកម្មជនសិទ្ធិមនុស្សដោយឯករាជ្យ

ជុំវិញការបិទគេហទំព័រ KI-Media និង blogspot.com

ឆ្នាំ២០១០ចំនួនអ្នកទោសស្លាប់ក្នុងពន្ធនាគារកើនឡើង

បុព្វហេតុរបស់សមាគមអ្នកប្រជាធិបតេយ្យ

ដង្ហែក្បួនទាមទារសេរីភាពឲ្យសកម្មជនកម្មករនៅគុកព្រៃស

ពលរដ្ឋប្តឹងទាហាននៅឧត្តរមានជ័យថាប្រើអំពើហិង្សា

## រឿងដែលគេអានច្រើនបំផុត

- រយៈពេល២៦ឆ្នាំនៃការកាន់អំណាច
- ក្រសួងមហាផ្ទៃឃាត់ខ្លួនឧត្តមសេ
- ហ៊ុន សែន ព្រមានចាប់អ្នកវិភាគសុ
- ជុំវិញការបិទគេហទំព័រ KI-Media និង blogspot.co
- ក្រុមអារលឿងថៃប្រមូលផ្តុំគ

## រឿងដែលគេអ៊ីម៉េលច្រើនបំផុត

បន្តទៀតថា សេចក្តីព្រាងច្បាប់នេះនឹងអនុញ្ញាតឲ្យថៅកែរោងចក្រអាចបញ្ឈប់សហជីពក្នុងរោងចក្រខ្លួនបាន ប្រសិនបើរោងចក្រមិនពេញចិត្តនឹងសហជីព។

អ្នកនាំពាក្យអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស លោក ទិត្យ សុផា នៅថ្ងៃអាទិត្យម្សិលមិញនេះ មានប្រសាសន៍ថា សេចក្តីព្រាងច្បាប់សមាគម និងសហជីពធ្វើឡើងដើម្បីពង្រឹងការអនុវត្តច្បាប់នៅកម្ពុជា។ លោកបន្តថា កន្លងមកមានអង្គការសមាគមមួយចំនួនបានប្រើប្រាស់ថវិកាជំនួយបរទេសមិនសមស្រប។

សេចក្តីថ្លែងការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាបន្តទៀតថា ចាប់តាំងពីការបោះឆ្នោតឆ្នាំ២០០៨ មក រដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់តុលាការជាឧបករណ៍ ដើម្បីគាបសង្កត់ និងបង្រ្កាបដល់សេរីភាពបញ្ចេញមតិនៅកម្ពុជា។ របាយការណ៍ស្តីពីសិទ្ធិសេរីភាពរបស់អង្គការឃ្លាំមើលសិទ្ធិសេរីភាពពិភពលោក ដែលមានឈ្មោះថា Freedom House បានរកឃើញថា ការរឹតត្បិតសិទ្ធសេរីភាពនៅកម្ពុជាកំពុងកើនឡើង។ អង្គការ Freedom House បានចាត់ចំណាត់ថ្នាក់កម្ពុជាបិតក្នុងចំណោមប្រទេសចំនួន ២៥ប្រទេស ដែលសិទ្ធិសេរីភាពផ្នែកខាងស៊ីវិល និងនយោបាយ ត្រូវបានក្តោបក្តាប់យ៉ាងតឹងរ៉ឹង។

ប្រទេសកម្ពុជាបិតក្នុងចំណោមបណ្តាប្រទេស ភូមា ចិន ឡាវ កូរ៉េខាងជើង និងវៀតណាម ដែលជាប្រទេសត្រូវគេចាត់ថា គ្មានសេរីភាព។

ទោះបីជាយ៉ាងក៏ដោយ លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា កាលពីថ្ងៃទី២០ មករា ឆ្នាំ២០១១ មានប្រសាសន៍ថា ប្រទេសកម្ពុជាកំពុងទទួលបាននូវសិទ្ធិសេរីភាពពេញលេញ ទោះបីជាមានការតវ៉ាថា កម្ពុជាគ្មានសេរីភាពក៏ដោយ។ លោកបន្តទៀតថា កម្ពុជាចាំបាច់បញ្ចប់សង្រ្គាម និងការបណ្តុះបណ្តាលធនធានមនុស្សដើម្បីឈានទៅរកសេរីភាព និងប្រជាធិបតេយ្យ។

Freedom House ចាត់ទុកកម្ពុជាជាប្រទេសគ្មានសេរីភាព ដោយសាររដ្ឋាភិបាលកម្ពុជាកំពុងក្តោបក្តាប់រាល់ដំណើរការនៃការបោះឆ្នោត ការគំរាមកំហែងមន្ត្រីអង្គការស៊ីវិល និងការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការខ្មែរក្រហម។

ទាក់ទងនឹងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល រដ្ឋាភិបាលកម្ពុជាធ្លាប់បានប្រកាសរួចហើយថា រដ្ឋាភិបាលកម្ពុជាគ្មានបំណងអាក្រក់ប្រឆាំងនឹងសមាគម អង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជានោះទេ។ ក្នុងកិច្ចពិភាក្សាមួយរវាងរដ្ឋាភិបាលកម្ពុជា និងក្រុមមន្ត្រីអង្គការសង្គមស៊ីវិលនៅកម្ពុជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានប្រកាសថា រដ្ឋាភិបាលកម្ពុជាគ្មានបំណងដើម្បីត្រួតត្រាអង្គការសង្គមស៊ីវិលនោះទេ។

លោកបន្តទៀតថា ប្រសិនបើរដ្ឋាភិបាលមានបំណងចង់គំរាមកំហែងសមាគម ឬអង្គការសង្គមស៊ីវិលនោះ រដ្ឋាភិបាលមិនចាំបាច់ត្រូវការវត្តមានអង្គការទាំងនោះនៅកម្ពុជានោះទេ។ បើទោះជាមានការថ្លែងអះអាងពីលោកឧបនាយករដ្ឋមន្ត្រី ស ខេង បែបនេះក្តី មន្ត្រីអង្គការមិនមែនរដ្ឋាភិបាលបានឲ្យដឹងថា អ្វីដែលសំខាន់នោះ គឺខ្លឹមសារលោយលក្ខណ៍អក្សរ ដែលគេត្រូវចែងឲ្យបានច្បាស់នៅក្នុងច្បាប់ មិនមែនការប្រកាសសន្យាផ្ទាល់មាត់នោះទេ។

នៅក្នុងកិច្ចប្រជុំមួយនាពេលថ្មីៗនេះ រវាងមន្ត្រីសង្គមស៊ីវិល និងមន្ត្រីរដ្ឋាភិបាល មានការពិភាក្សាគ្នាជាច្រើនចំណុច ទៅលើសេចក្តីព្រួយបារម្ភរបស់អង្គការសមាគម។ ប៉ុន្តែគេនៅមិនទាន់ដឹងច្បាស់ទេថា តើរដ្ឋាភិបាលនឹងទទួលយកអនុសាសន៍កែលម្អសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលស្នើឡើងដោយក្រុមសង្គមស៊ីវិលបានប៉ុន្មាននោះទេ៕

*Copyright © 1998-2011 Radio Free Asia. All rights reserved.*

បោះពុម្ព   អ៊ីម៉ែល

**មតិ**


- រយៈពេល២៦ឆ្នាំនៃការកាន់អំណាច
- ក្រសួងមហាផ្ទៃឃាត់ខ្លួនឧត្តមសេ
- មានម្ចាស់ដីជាច្រើនត្រូវចាប់
- ជុំវិញការបិទគេហទំព័រ KI-Media និង blogspot.co
- វៀតណាមសម្លាប់ខ្មែរក្រោម២នាក់

Click here to add your own comment

មើលមតិទាំងអស់.

បញ្ចូលមតិរបស់អ្នកដោយបំពេញទម្រង់ខាងក្រោមជាអក្សរសុទ្ធ។
មតិនឹងត្រូវសម្រេចដោយអ្នកសម្របសម្រួលនិងអាចចុះផ្សាយបានយោងតាមលក្ខខណ្ឌនៃការប្រើប្រា
មតិនឹងមិនអាចមើលឃើញភ្លាមៗទេ។
វិទ្យុអាស៊ីសេរីមិនទទួលខុសត្រូវចំពោះខ្លឹមសារនៃមតិដែលបានចុះផ្សាយឡើយ។

ឈ្មោះ (ដាក់ឬមិនដាក់ក៏បាន)

ក្រុង (ដាក់ឬមិនដាក់ក៏បាន)

Captcha (ត្រូវតែបំពេញ)

34AV2HF

*សូមវាយបញ្ចូលតួអក្សរដែលអ្នកឃើញនៅក្នុងរូបភាព*

មតិ (ត្រូវតែបំពេញ)

Submit